# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
# ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 25-May-2011, 15:00
CMS/CFO: Uch Arun

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ

ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្តីលោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១១

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ អង្គជំនុំជម្រះ **សាធារណៈ/Public**

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

## ញត្តិគាំទ្រដល់ញត្តិរបស់ អៀង សារី សុំដាក់បន្ថែមវិធានបទថ្មីៗសម្រាប់សវនាការនៅក្នុងកម្មវិធីសវនាការ និងសំណើសុំដាក់បន្ថែមប្រធានបទថ្មីៗ

---

<u>ដាក់ដោយ</u>៖

**ក្រុមមេធាវីការពារក្តី នួន ជា**

សុន អរុណ

Michiel PESTMAN
Victor KOPPE
Andrew IANUZZI
Jasper PAUW

ព្រុំ ផល្លា

Annebrecht VOSSENBERG

Alejandra CHAPA (កម្មសិក្សាការីច្បាប់)

<u>ផ្ញើជូន</u>៖

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**ក្រុមមេធាវីការពារក្តីទាំងអស់**

## I. សេចក្តីផ្តើម

១. អនុលោមតាមវិធាន ៩២ នៃវិធានផ្ទៃក្នុងរបស់ អវតក (“វិធាន”)[1] ក្រុមមេធាវីការពារក្តីជនជាប់ចោទ នួន ជា (“ជនជាប់ចោទ”) តទៅនេះសូមដាក់ញត្តិរបស់ខ្លួន ដើម្បីគាំទ្រដល់ញត្តិរបស់ អៀង សារី សុំឱ្យដាក់បន្ថែមប្រធានបទថ្មីៗសម្រាប់សវនាការទៅក្នុងកម្មវិធីសវនាការ (“ញត្តិរបស់ អៀង សារី”)[2] និងសំណើសុំដាក់បន្ថែមប្រធានបទថ្មីៗ ។ ដូចមានមូលហេតុដែលបញ្ជាក់នៅខាងក្រោម មេធាវីការពារក្តីពិចារណាថាការបន្ថែមប្រធានបទដាក់លាក់ទៅក្នុងកម្មវិធីសវនាការ គឺចាំបាច់ដើម្បីធានាដល់ការជំនុំជម្រះ នួន ជា ដោយយុត្តិធម៌ ដែលតម្រូវការពិភាក្សាទូលំទូលាយទៅលើព្រឹត្តិការណ៍ដែលពាក់ព័ន្ធ និងស្ថានសម្រាលផងដែរ ។

## II. អង្គហេតុពាក់ព័ន្ធ

២. នៅថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១១ ក្រុមការពារក្តី អៀង សារី បានស្នើសុំឱ្យដាក់បន្ថែមទៅក្នុងកម្មវិធីសវនាការនូវប្រធានបទៈ (ក) វប្បធម៌ និងប្រជាសាស្ត្រនៃប្រទេសកម្ពុជា ចាប់ពីអំឡុងពេលមុនសម័យអាណានិគមរហូតដល់ឆ្នាំ១៩៧៥, (ខ)ប្រវត្តិសាវតារ, ការក្រោកបះបោរ និងគោលបំណងរបស់ក្រុមឆ្វេងនិយមកម្ពុជា រួមទាំងពួកឥស្សរៈ, គណបក្សសាធារណៈរដ្ឋខ្មែរ, បក្សពលករកម្ពុជា និងបក្សកុម្មុយនីស្តកម្ពុជា (“CPK”) (គ) បរិបទជុំវិញឥរិយាបថចំពោះព្រះពុទ្ធសាសនានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ, ឃ) បរិបទជុំវិញឥរិយាបថចំពោះជនជាតិចាមនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និង (ង) បរិបទជុំវិញឥរិយាបថចំពោះជនជាតិ វៀតណាមនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ, (ច) ការទទួលស្គាល់របបកម្ពុជាប្រជាធិបតេយ្យថាជារដ្ឋាភិបាលស្របច្បាប់ដោយអង្គការសហប្រជាជាតិ, (ឆ) ចរិតលក្ខណៈរបស់

---

[1] សូមមើលវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៧) ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១១ ។

[2] ឯកសារលេខ **E-89** “សំណើរបស់លោក អៀង សារី សុំឱ្យដាក់បន្ថែមប្រធានបទថ្មីៗសម្រាប់សវនាការនៅក្នុងកម្មវិធីសវនាការ” ថ្ងៃទី២៣ ខែ ឧសភា ឆ្នាំ ២០១១ ERN 00696988-00698993 “ញត្តិរបស់អៀង សារី”។

រដ្ឋាភិបាលនៅក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា[3] (ដែលហៅជារួមថាប្រធានបទរបស់ អៀង សារី)។

៣. នៅថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១ មេធាវីការពារក្ដីដាក់ "សំណើរួមលើកទី១ សុំឲ្យបំពេញកិច្ចស៊ើបសួរបន្ថែម" ដោយបានធ្វើការកត់សម្គាល់ (ក្នុងចំណោមបញ្ហាដទៃទៀត) ថាការយល់ឃើញរបស់ក្រុមមេធាវីការពារក្ដីថាករណីត្រូវតែចែកជាបីប្រភេទធំៗ[4] ដែលត្រូវបានរៀបចំដូចខាងក្រោម៖

(ក) *ការជំនុំជម្រះក្ដីដោយយុត្តិធម៌:* ចរិតលក្ខណៈស្ថាប័ន យុត្តាធិការ និងដំណើរការនីតិវិធី និងគុណភាព ដំណើរការនីតិវិធីនៅពេលបច្ចុប្បន្ន និងនៅថ្ងៃខាងមុខ[5] ។

(ខ) *បរិបទ:* សេណារីយ៉ូផ្នែកប្រវត្តិសាស្ត្រ ភូមិសាស្ត្រនយោបាយ សេដ្ឋកិច្ចសង្គម ប្រជាសាស្ត្រ យោធា និងច្បាប់និង/ឬស្ថាប័ន រួមទាំងបក្សកុម្មុនីស្ដកម្ពុជាដែលប៉ះពាល់ដោយផ្ទាល់ ឬ ដោយប្រយោលដល់ប្រទេសកម្ពុជា *នៅមុន ក្នុងអំឡុងពេលនិងក្រោយរបបកម្ពុជាប្រជាធិបតេយ្យ*[6]

---

[3] ញត្តិរបស់ អៀង សារី នៅកថាខណ្ឌទី ៣ និងទី៥ ។

[4] ឯកសារលេខ E **E-88** "សំណើរួមលើកទី០១ សុំបំពេញកិច្ចស៊ើបសួរបន្ថែម" ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១, ERN 00698309-00698324 នៅកថាខណ្ឌទី ០៦ ។

[5] ដូចខាងលើ នៅកថាខណ្ឌទី៦(ក) ។ *កំណត់សំគាល់:* ប្រភេទនេះរួមបញ្ចូលទាំង និងក្នុងចំណោមបញ្ហាដទៃទៀត អនុប្រភេទបន្ទាប់: ការចោទប្រកាន់ពីអំពើពុករលួយ, ការតែងតាំងចៅក្រម, ការធ្វើឲ្យស្របច្បាប់នៃភស្តុតាង រួមទាំងខ្សែរចង្វាក់នៃការគ្រប់គ្រងភស្តុតាង ការលាតត្រដាងសម្ភារៈភស្តុតាងដោយរដ្ឋាភិបាលបរទេស ឯករាជ្យភាព អនាគតិ និងសច្ចភាពរបស់តុលាការ និងការស៊ើបអង្កេតរបស់ កសចស រួមទាំងវិសាលភាព និងគុណភាព ការចូលជ្រៀតជ្រែកខាងនយោបាយ ការជ្រើសរើសជនសង្ស័យសម្រាប់ការជំនុំជម្រះ ការជ្រើសរើសភស្តុតាង យុត្តាធិការបទល្មើស/យុត្តាធិកាពេលវេលា/យុត្តាធិកាបុគ្គល និងការផ្ទៀងផ្ទាត់កំណត់ហេតុស្តាប់ចម្លើយសាក្សី ។

[6] ដូចខាងលើនៅកថាខណ្ឌទី៦ (ខ) ។ *កំណត់សំគាល់:* ប្រភេទនេះ រួមបញ្ចូលអនុប្រភេទបន្ទាប់: រចនាសម្ព័ន្ធបញ្ជារបស់បក្សកុម្មុនីស្ដកម្ពុជា រួមទាំងរចនាសម្ព័ន្ធផ្សេងដូចមានចែងនៅក្នុងដីកាបញ្ជូនរឿងទៅជម្រះ, រចនាសម្ព័ន្ធ និង ការប្រព្រឹត្តទៅរបស់ស្ថាប័ននានារបស់បក្សកុម្មុនីស្ដកម្ពុជា និងមន្ទីរសន្តិសុខ, ការដឹង និងការជាប់ព័ន្ធរបស់មេដឹកនាំកម្ពុជាប្រជាធិបតេយ្យនៅគ្រប់ថ្នាក់, គោលបំណងរបស់បក្សកុម្មុនីស្តកម្ពុជា, ស្ថានភាពរស់នៅៗកម្ពុជា ជាពិសេសនៅពេលបក្សកុម្មុនីស្ដកម្ពុជាចូលកាន់អំណាចនៅខែមេសា ឆ្នាំ១៩៧៥, វត្តមាន/ការជាប់ពាក់ព័ន្ធរបស់បរទេសនៅកម្ពុជា រួមទាំងសកម្មភាពរបស់ភ្នាក់

(គ) *ការទទួលខុសត្រូវរបស់ នួន ជា:* ការដឹង ចេតនា ការចូលរួម មុខតំណែង និង តួនាទី តាមការសន្និដ្ឋានរបស់ជនជាប់ចោទទាក់ទងនឹងសកម្មភាពព្រហ្មទណ្ឌដែលមិនច្បាស់ ដែលត្រូវបានពិពណ៌នានៅផ្នែកជាច្រើននៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ រួមបញ្ចូលទាំងសកម្មភាពព្រហ្មទណ្ឌនៅមន្ទីរស-២១ ព្រមទាំងស្ថានសម្រាលពាក់ព័ន្ធនានា រួមទាំងភស្តុតាងលើចរិតលក្ខណៈផងដែរ[7] ។

៤. ដោយឡែក អង្គជំនុំជម្រះសាលាដំបូងបានគូសបញ្ជាក់ថាអង្គជំនុំជម្រះសាលាដំបូងមានបំណងដំណើរការសវនាការក្នុងលក្ខណៈដាក់កម្រិតតឹងរ៉ឹងជាងមុន[8] ។

## III. ច្បាប់ពាក់ព័ន្ធ

៥. ក្នុងការវាយតម្លៃភាពពាក់ព័ន្ធរបស់កិច្ចដែលបានស្នើសុំឲ្យស៊ើបសួរដោយក្រុមមេធាវីការពារក្តី អង្គជំនុំជម្រះសាលាដំបូង ត្រូវបានណែនាំឲ្យពិនិត្យមើលយុត្តិសាស្ត្រដែលបង្កើតឡើងនៅកម្រិតអន្តរជាតិ ដោយបានគូសបញ្ជាក់ថា "អំពើដែលកើតឡើងនៅមុនយុត្តាធិការពេលវេលា

---

ងារចារកម្មផ្សេងៗ ជាពិសេសការពាក់ព័ន្ធរបស់វៀតណាម, អត្ថិភាពនៃជម្លោះប្រដាប់អាវុធ, ព្រះរាជតួនាទីរបស់ព្រះរាជបីតានរោត្តម សីហនុ និងធាតុផ្សំសំខាន់របស់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។

[7] ដូចខាងលើនៅកថាខណ្ឌទី ៦(គ) ។ កត់សំគាល់: ប្រភេទនេះរួមបញ្ចូលទាំងសក្ខីកម្មលើកមុន (សក្ខីកម្មដែលនឹងមកដល់ក្នុងពេលខាងមុខ) និងភាពជឿជាក់បានរបស់ បដិសាក្សី ជាពិសេស ឌុច ។

[8] សូមមើលឯកសារលេខ E-1/2.1 "ប្រតិចារិត, កិច្ចប្រជុំរៀបចំសវនាការ" ថ្ងៃទី៥ ខែមេសា ឆ្នាំ២០១១, ERN 00664215-00664345 (ប្រតិចារិត TMM), ៥២-១៧("នៅដំណាក់កាលនេះ អង្គជំនុំជម្រះសាលាដំបូងសូមគូសបញ្ជាក់ជាមុនអំពីលំដាប់លំដោយនៃការចាប់ផ្តើមកិច្ចសវនាការ ។ អង្គជំនុំជម្រះសាលាដំបូងសូមជូនដំណឹងឲ្យភាគីបានដឹងអំពីចេតនារបស់អង្គជំនុំជម្រះ ក្នុងការបើកសវនាការលើអង្គសេចក្តីទៅតាមលំដាប់លំដោយដូចតទៅ: ទី១ រចនាសម្ព័ន្ធរបស់កម្ពុជាប្រជាធិបតេយ្យ, ទី២ តួនាទីរបស់ជនជាប់ចោទម្នាក់ៗក្នុងអំឡុងពេលនៅមុនការបង្កើតកម្ពុជាប្រជាធិបតេយ្យ រួមទាំងនៅពេលណាដែលជនជាប់ចោទទទួលបានតួនាទីទាំងនេះផង, ទី៣ តួនាទីរបស់ជនជាប់ចោទនីមួយៗនៅក្នុងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ការទទួលខុសត្រូវរបស់ជនជាប់ចោទម្នាក់ៗ កម្រិតនៃសិទ្ធិអំណាចរបស់ពួកគេ និងខ្សែរយៈនៃការទំនាក់ទំនងនៅទូទាំងយុត្តាធិការពេលវេលារបស់ អវតក និងទី៤ គោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យទៅលើបញ្ហាដែលបានលើកឡើងនៅក្នុងដីកាបញ្ជូនរឿងទៅជម្រះ") ។

អាចត្រូវបានលើកមកសំអាងក្នុងករណីដែលភស្តុតាងមានបំណង "បញ្ជាក់ពីអង្គហេតុ"[9] ។ តាមពិត កសព បានអះអាងកាលពីលើមុនពីសារៈសំខាន់របស់ធាតុផ្សំផ្នែកអង្គហេតុ ដើម្បីយល់ឲ្យបានពេញលេញនូវបញ្ហានៅក្នុងករណីនេះ[10]។ ទាក់ទងនឹងចំណុចនេះ វិធាន ៥៥(២) យោងទៅលើ "អង្គហេតុដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបន្ថែមបញ្ជូនរឿងឲ្យស៊ើបសួរ" ត្រូវតែបានបកស្រាយឲ្យបានធំទូលាយ និងស្របតាមចរិតលក្ខណៈ និងទំហំនៃដំណើរការនីតិវិធីបច្ចុប្បន្ន ។

## IV. អំណះអំណាង

### ក. សំណើនេះអាចទទួលយកបាន

៦. សំណើនេះ ត្រូវបានដាក់យ៉ាងត្រឹមត្រូវ ស្របតាមវិធាន៩២ នៃវិធានផ្ទៃក្នុង ហើយអង្គជំនុំជម្រះសាលាដំបូងមានឆន្ទានុសិទ្ធិដោះស្រាយលើសំណើនេះ។

### ខ. ប្រធានបទរបស់លោក អៀង សារី គួរតែដាក់បញ្ចូលទៅក្នុងកម្មវិធីសវនាការ

---

[9] សូមមើលឯកសារ D-365/2/1 "សារណាបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាការឆ្លើយតបទៅនឹងដីការបស់សហចៅក្រមស៊ើបអង្កេត ទាក់ទងនឹងសំណើសុំឲ្យដាក់នៅក្នុងសំណុំរឿងនូវសម្ភារៈជាភស្តុតាងបន្ថែម ដែលជួយដល់ការបង្ហាញការដឹងពីឧក្រិដ្ឋកម្មរបស់ជនជាប់ចោទ" ចុះថ្ងៃទី ៥ ខែមេសា ឆ្នាំ២០១១ ERN 00508881–00508908 នៅកថាខណ្ឌទី១១ (សម្រង់ឯកសារ D-300 "ដីកាសម្រេចលើសំណើ D-153, D-172, D-174, D-178 & D-284', ចុះថ្ងៃទី១២ ខែមករា ឆ្នាំ ២០១០ ERN 00428047–00428058 នៅកថាខណ្ឌទី ៩ (លើកមកសំអាង ICTR-99-52-A, *រដ្ឋអាជ្ញាតទល់ Nahimana* និងអ្នកដទៃ សាលាដីកាចុះថ្ងៃទី២៨ វិច្ឆិកា ឆ្នាំ២០០៧ នៅកថាខណ្ឌទី៣១៥) ។ សូមមើលផងដែរ **D-315/1/1** "បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកា កសចសស លើសំណើរបស់ នួន ជា សុំឲ្យស៊ើបអង្កេតពាក់ព័ន្ធនឹងរដ្ឋាភិបាលបរទេស" ថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ ២០១០, ERN 00456083-00456100 "បណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធតរដ្ឋាភិបាលបរទេស" នៅកថាខណ្ឌទី ១២ ។

[10] សូមមើលឯកសារ D-365 "សំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យដាក់បញ្ចូលក្នុងសំណុំរឿងនូវភស្តុតាងបន្ថែម ដែលអាចជួយដល់ការបង្ហាញការដឹងពីឧក្រិដ្ឋកម្មរបស់ជនជាប់ចោទ" ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១១ ERN 00478047–00478055 នៅកថាខណ្ឌទី១ ។

៧. មេធាវីការពារក្តីសូមដាក់បញ្ចូល និងយោងសំអាងហេតុ និងសំណើសុំដំណោះស្រាយដែលមាននៅក្នុងញត្តិរបស់ អៀង សារី ។

**គ. ប្រធានបទបន្ថែមគួរតែដាក់បញ្ចូលទៅក្នុងកម្មវិធីសវនាការ**

៨. បន្ថែមពីលើប្រធានបទរបស់លោក អៀង សារី មេធាវីការពារក្តីសូមដាក់បន្ថែមប្រធានបទមួយចំនួនទៀតទៅក្នុងកម្មវិធីសវនាការ ។ ប្រធានបទទាំងនេះ អាចត្រូវបានដាក់ជាក្រុមរួមគ្នាតាមចំណងជើងដូចខាងក្រោម[11]៖

ក. *ក្តីកង្វល់ទាក់ទងនឹងការជំនុំជម្រះក្តីដោយយុត្តិធម៌:* ចរិតលក្ខណៈស្ថាប័ន យុត្តាធិការ និងដំណើរការនីតិវិធី និងគុណភាពនៃដំណើរការនីតិវិធីនៅវេលាមកដល់ពេលបច្ចុប្បន្ន និងនៅថ្ងៃខាងមុខ[12]។

ខ. *ធាតុផ្សំអង្គហេតុពាក់ព័ន្ធ:* សេណារីយ៉ូផ្នែកប្រវត្តិសាស្ត្រ ភូមិសាស្ត្រនយោបាយ សង្គមសេដ្ឋកិច្ច ប្រជាសាស្ត្រ យោធា និងច្បាប់និង/ឬស្ថាប័ន រួមទាំងសេនារីយ៉ូ និងស្ថាប័នរបស់បក្សកុម្មុនីស្តកម្ពុជា និងសេនារីយ៉ូ ដែលបានកើតឡើងក្នុងឬប្រតិបត្តិការ *ក្រៅ* ដែនដីកម្ពុជា ដែលប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោលដល់ប្រទេសកម្ពុជា *នៅមុន ក្នុងអំឡុងពេល និងក្រោយរបបកម្ពុជាប្រជាធិបតេយ្យ*[13] ។

---

[11] វាមានការត្រួតគ្នាក្នុងកម្រិតណាមួយជាមួយនឹងប្រធានបទដែលបានលើកឡើងដោយក្រុមមេធាវីការពារក្តីលោក អៀង សារី។

[12] ប្រភេទនេះ រួមបញ្ចូលអនុប្រភេទបន្ទាប់ដូចតទៅនេះ៖ ការចោទប្រកាន់អំពីអំពើពុករលួយ, ការតែងតាំងចៅក្រម, ការធ្វើឲ្យស្របច្បាប់នៃភស្តុតាង រួមទាំងខ្សែរចង្វាក់នៃការគ្រប់គ្រង ការមិនព្រមលាតត្រដាងសម្ភារៈភស្តុតាងដោយរដ្ឋាភិបាលបរទេសឯករាជ្យភាពអនាគតិ និងសចរិតភាពរបស់តុលាការ និងការស៊ើបអង្កេតរបស់ កសចស រួមទាំងវិសាលភាព និងគុណភាពនៃការស៊ើបអង្កេត ការជ្រៀតជ្រែកខាងនយោបាយ ការជ្រើសរើសជនសង្ស័យសម្រាប់ការចោទប្រកាន់ ការជ្រើសរើសភស្តុតាង យុត្តាធិការបទល្មើស/យុត្តាធិកាពេលវេលា/យុត្តាធិកាបុគ្គល និងការផ្ទៀងផ្ទាត់កំណត់ហេតុស្តាប់ចម្លើយសាក្សី ។

[13] ប្រភេទនេះ រួមបញ្ចូលអនុប្រភេទបន្ទាប់ដូចតទៅនេះ៖ ស្ថានភាពរស់នៅរបស់ប្រជាជនកម្ពុជា ជាពិសេសនៅពេលបក្សកុម្មុនីស្តកម្ពុជាចូលកាន់អំណាចនៅខែ មេសា ឆ្នាំ១៩៧៥ និងក្នុងរយៈពេលបន្តមកទៀត, វត្តមាន/ការជាប់ពាក់ព័ន្ធរបស់បរទេសនៅកម្ពុជារួមទាំងសកម្មភាពរបស់ភ្នាក់ងារចារកម្មណាមួយ ជាពិសេសការពាក់ព័ន្ធរបស់វៀតណាម, គោលដៅវិជ្ជ

៩. បន្ថែមពីអំណះអំណាងដែលបានលើកឡើងដោយក្រុមមេធាវីការពារក្តីលោក អៀង សារី មេធាវីការពារក្តីយល់ឃើញថាការពិភាក្សាឲ្យបានស៊ីជម្រៅលើប្រធានបទដែលបានលើកឡើងដោយមេធាវីការពារក្តី គឺដើម្បីផ្តល់ឲ្យ នួន ជា នូវការជំនុំជម្រះក្តីមួយប្រកបដោយយុត្តិធម៌ ។ ការជំនុំជម្រះក្តីបែបនេះ ទាមទារឲ្យមានការពិចារណាសមស្របលើបញ្ហាភស្តុតាងពាក់ព័ន្ធទាំងអស់ និងស្ថានសម្រាលផងដែរ ។ ការពិចារណាត្រឹមតែប្រធានបទដែលបានស្នើសុំដោយអង្គជំនុំជម្រះសាលាដំបូង[14] នឹងនាំឲ្យមានការវាយតម្លៃដែលមិនពេញលេញ និងមិនពេញលក្ខណៈលើអង្គហេតុដែល នួន ជា កំពុងត្រូវបានគេចោទប្រកាន់ ។ បើឈរលើគោលគំនិតនៃការសន្សំសំចៃថវិកាតុលាការ ដំណោះស្រាយដែលមានលក្ខណៈតូចចង្អៀតរបស់អង្គជំនុំជម្រះសាលាដំបូង នឹងមិនធ្វើឲ្យមានយុត្តិធម៌ចំពោះភាពស្មុគស្មាញនៃស្ថានភាពដែលប្រទេសកម្ពុជាកំពុងប្រឈមមុខ និងមេដឹកនាំរបស់ប្រទេសនេះចាប់ពីឆ្នាំ១៩៦០មក និងជាពិសេសក្នុងសម័យកម្ពុជាប្រជាធិបតេយ្យបានឡើយ។ ដើម្បីឲ្យមានការយល់យ៉ាងពេញលេញពីប្រវត្តិសាស្ត្រ និងការវាយតំលៃយ៉ាងត្រឹមត្រូវលើអ្វីដែលបានកើតឡើងក្នុងពេលវេលាដែលបានពិ ពណ៌នាដោយយុត្តាធិការពេលវេលានៅ អវតក (១៩៧៥-១៩៧៩) និងដើម្បីវាយតម្លៃឲ្យបាន ត្រឹមត្រូវអំពីព្រឹត្តិការណ៍ដែលទាញចេញពីទស្សនវិស័យច្បាប់ វាតម្រូវឲ្យមានការពិចារណាដែលស៊ីជម្រៅជាងនេះអំពីព្រឹត្តិការណ៍នានាដែលបានកើតឡើងមុនរដ្ឋាភិបាលកម្ពុជាប្រជា

---

មានរបស់បក្សកុម្មុយនីស្តកម្ពុជា មុនពេលឡើងកាន់អំណាច, គោលបំណង និងឥទ្ធិពលនៃការទំលាក់គ្រាប់បែករបស់សហរដ្ឋអា មេរិកលើប្រទេសកម្ពុជានៅចុងទសវត្សឆ្នាំ១៩៦០ និងដើមទសវត្សឆ្នាំ១៩៧០ ទាក់ទងនឹងការស្លាប់ និងរបួសមនុស្ស និងការខូច ខាតសម្ភារៈ (រួមបញ្ចូលទាំងឥទ្ធិពលលើសមត្ថភាពផលិតអាហារ) និងឥទ្ធិពលលើស្ថានភាពរស់នៅ និងផ្នត់គំនិតរបស់ប្រជាជន កម្ពុជាក្នុងតំបន់ដែលរងការប៉ះពាល់។

[14] សូមមើលកថាខណ្ឌទី៤, ដូចខាងលើ។

ធិបតេយ្យឡើងកាន់អំណាច និងព្រឹត្តិការណ៍ពាក់ពាន់ដ៏ទៃទៀតបន្ទាប់ពីរបបនេះបានដួលរលំ[15]។

## V. សេចក្តីសន្និដ្ឋាន និងសំណើ

១០. អាស្រ័យលើហេតុផលខាងលើ មេធាវីការពារក្តីសូមស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងបន្ថែមប្រធានបទរបស់លោក អៀង សារី និងប្រធានបទដែលបានលើកឡើងនៅទីនេះ (ត្រង់កថាខណ្ឌទី៨) ចូលក្នុងកម្មវិធីសវនាការ ។ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងបដិសេធមិនទទួលយកញត្តិនេះទេ នោះមេធាវីការពារក្តីស្នើសុំឱកាសដើម្បីដាក់សារណាផ្ទាល់មាត់បន្ថែមទៀតទាក់ទងនឹងបញ្ហានេះនៅពេលសវនាការបឋម។

**សហមេធាវីការពារក្តីលោក នួន ជា**

**សុន អរុណ** Michel PESTMAN & Victor KOPPE

[15] កំណត់សំគាល់: នៅពេលដែលការជំនុំជម្រះក្តី ចេះតែដំណើរការទៅមុខ ប្រធានបទបន្ថែមទៀត អាចនឹងលេចឡើងដែលសមនឹងទទួលបានការពិភាក្សាឲ្យបានដិតដល់ដោយភាគី។ ដូច្នេះ មេធាវីការពារក្តី សូមរក្សា សិទ្ធិស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងពិចារណាលើប្រធានបទបន្ថែមទៀត។